# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

## របាយការណ៍កិច្ចប្រជុំ
## ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែតុលា

១. **ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃសុក្រ ១៣កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣

២. **ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាញ(Zoom)

៣. **ប្រធាន និងសមាសភាពចូលរួម ៖**

៣.១ ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន៣០រូប និងតាមប្រព័ន្ធអនឡាយចំនួន៣២រូប សរុបចំនួន៦២រូប។

៤. **របៀបវារៈ៖**

៤.១-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២-បទបង្ហាញស្តីពីៈ

- យុទ្ធវិធីក្នុងការធ្វើតេស្តរកមេរោគអេដស៍
- លទ្ធផលនៃការអនុវត្តនៃការបង្ការ និងធ្វើតេស្តរកមេរោគអេដស៍ តាមល្បាក់សេវា ក្រុមប្រឈមមុខខ្ពស់ បង្ហាញដោយ **លោកវេជ្ជបណ្ឌិត ជា ចាន់កុសលមុនី** ប្រធានផ្នែកធ្វើតេស្តរកមេរោគអេដស៍ នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងមេរោគអេដស៍ សើស្បែក និងកាមរោគ ក្រសួងសុខាភិបាល ។

៤.៣- មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. លទ្ធផល ៖**

**៥.១** ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ទទួលបន្ទុកដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែតុលា ឆ្នាំ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ដំណើរការនៃកិច្ចប្រជុំមាន៖

**ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ បានមានប្រសាសន៍ជូនអង្គប្រជុំឱ្យបានជ្រាបថា កិច្ចប្រជុំថ្ងៃនេះ បានផ្តោតលើ វឌ្ឍនភាព និងការប្រឈម ការធ្វើតេស្តឈាមរកមេរោគអេដស៍ នៅក្នុងប្រទេសកម្ពុជា។

៥.២ **លោកវេជ្ជបណ្ឌិត ជា ច័ន្ទកុសលមុនី** ប្រធានផ្នែកធ្វើតេស្តរកមេរោគអេដស៍ នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងមេរោគអេដស៍ សើស្បែក និងកាមរោគ ក្រសួងសុខាភិបាល បានផ្តល់នូវរបាយការណ៍សមិទ្ធផលនៃការធ្វើតេស្តរកមេរោគអេដស៍ បានបង្ហាញពីយុទ្ធវិធី ក្នុងការធ្វើតេស្តរកមេរោគអេដស៍ រួមមាន៖

- ការធ្វើតេស្តនៅសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តមេរោគអេដស៍ (VCCT) : សម្រាប់អតិថិជនដើរចូលខ្លួនឯង ឬអ្នកជំងឺដែលបញ្ជូនមកពីមណ្ឌលសុខភាព មន្ទីរពេទ្យ និងសហគមន៍ ដើម្បីធ្វើតេស្តបញ្ជាក់។
- ការធ្វើតេស្តនៅសេវាមន្ទីរពេទ្យ (HPITC) : សម្រាប់ធ្វើតេស្តដល់អ្នកជំងឺសម្រាកពេទ្យ ករណីតេស្តវិជ្ជមានត្រូវបញ្ជូនទៅទទួលលទ្ធផលនៅ VCCT។
- ការធ្វើតេស្តនៅសេវាមណ្ឌលសុខភាព : សម្រាប់ធ្វើតេស្តដល់អតិថិជនទូទៅ អ្នកជំងឺរបេង ស្ត្រីមានផ្ទៃពោះ និងដៃគូគាត់ករណីមានប្រតិកម្មត្រូវបញ្ជូនទៅធ្វើតេស្តបញ្ជាក់នៅសេវា VCCT ។
- ការធ្វើតេស្តនៅសេវាសហគន៍ (Community): សម្រាប់ធ្វើតេស្តដល់ក្រុមប្រឈមមុខខ្ពស់ ករណីមានប្រតិកម្មត្រូវបញ្ជូនទៅធ្វើតេស្តបញ្ជាក់នៅសេវា VCCT។
- ការធ្វើតេស្តនៅសេវាថែទាំ និងព្យាបាល (ART Service) សម្រាប់ដៃគូអ្នកជំងឺ។

- **លទ្ធផលការអនុវត្តការបង្ការ និងធ្វើតេស្តរកមេរោគអេដស៍ នៃក្រុមប្រជាជនគន្លឹះ**
  - អត្រាវិជ្ជមានមេរោគអេដស៍ តាមក្រុមប្រជាជនគន្លឹះ ដែលបានធ្វើតេស្តនៅសេវាសុខាភិបាលសាធារណៈឆ្នាំ២០២២មាន៖ ក្រុមស្ត្រីបម្រើនៅសេវាកម្សាន្តសប្បាយ (០,៧%) បុរសរួមភេទជាមួយបុរស (៣,៧%) និងក្រុមបំប្លែងភេទ (៦,០%)។ អត្រាវិជ្ជមានមេរោគអេដស៍រួមនៃក្រុមប្រជាជនគន្លឹះមិនមានការធ្លាក់ចុះទេ ដែលមានអត្រា ២,៣ % ក្នុងឆ្នាំ២០២១ ២,៦% (ឆ្នាំ២០២២) ២,២% (មករា-កញ្ញា ឆ្នាំ២០២៣)។

- អត្រាវិជ្ជមានមេរោគអេដស៍ តាមក្រុមប្រជាជនគន្លឹះ ដែលបានធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯងតាមសហគមន៍ ក្នុងឆ្នាំ២០២២មាន៖ ក្រុមបុរសរួមភេទនឹងបុរស (១០%) ក្រុមបំប្លែងភេទ (១៨%) ស្ត្រីបម្រើនៅសេវាកម្សាន្តសប្បាយ (៥%)។ ជារួមការតេស្តរកមេរោគអេដស៍ដោយខ្លួនឯង មានអត្រាប្រហាក់ប្រហែលគ្នាក្នុងឆ្នាំ២០២១ និងឆ្នាំ២០២២ ដែលមានអត្រា ១៣% (ឆ្នាំ២០២១) និង ១០%(ឆ្នាំ២០២២)។

- **មានកត្តាប្រឈមដើម្បីឱ្យការអនុវត្តសម្រេចបានជោគជ័យដូចជា៖**
  - ការគ្រប់គ្រងធ្វើតេស្តរកមេរោគអេដស៍នៅតាមវិស័យឯកជន នៅមានកម្រិត ជាពិសសការចែកចាយ(លក់) កញ្ចប់តេស្តរកមេរោគដោយខ្លួនឯង។
  - ការគ្រប់ដណ្តប់បទអន្តរាគមន៍នៅមានកំរិត ចំពោះក្រុមគោលដៅលាក់អត្តសញ្ញាណលាក់មុខ ក្រុមឯករាជ្យ ឬក្រុមធ្វើការចល័តពីហាងមួយទៅហាងមួយ ឬទីតាំងមួយទៅទីតាំងមួយ (កន្លែងដី ឃ្លាំងគេទុកចោល) ឬក្រុមគោលដៅ ពាក់ព័ន្ធគ្រឿងញៀន (ដូរលេខទូរស័ព្ទ) ឬទីកន្លែងប្រកបមុខរបរមិនជាក់លាក់ ឬការនាំដៃគូមកធ្វើតេស្ត។
- **មតិ យោបល់**

  បណ្តាញក្រុមបុរសស្រលាញ់បុរសមាន:
  - ស្ថានភាពមេរោគអេដស៍នៅតំបន់កោះពេជ្រ និងបឹងកក់មានការប្រែប្រួល។
  - ស្ថានភាពស្វែងរកដៃគូ តាមកម្មវិធីបុណ្យភូមិ មិនដូចមុនសម្រាប់TG ( បញ្ហាសុវត្ថិភាពការធ្វើដំណើរត្រឡប់មកផ្ទះវិញ)។
  - ករណី HIV ថ្មីកើតលើមិត្តកក្តិចំនួន៣នាក់រយៈពេល៣ខែចុងក្រោយនេះ( ទៅទទួលសេវាPrEP ) មិនប្រើស្រោម ទុកចិត្តដៃគូ ការបង្កកគ្រឿងស្រវឹងពីដៃគូ។
  - ករណី HIV ថ្មីកើតលើជនពិការភាពមានអាយុ ២២ឆ្នាំ ជាក្រុមអ្នកទទួលមិនមែនMSM
  - រដូវកាលនេះជារដូវកាលប្រើសេវា PrEP សម្រាប់ក្រុម MSM/TG ចាប់ពីខែ០៩ទៅកម្មវិធីបុណ្យភូមិ កម្មវិធីផ្សេងៗ ចេញវស្សា បុណ្យភ្ជុំបិណ្ឌ បុណ្យអុំទូក បុណ្យផ្សេងៗ។
  - TG កែភេទមិនប្រើប្រាស់ PrEP ការពារដោយពួកគាត់ប្រើអរម៉ូន ថ្នាំវីតាមីនច្រើន និងភ្ញៀវតម្រូវមិនឱ្យប្រើស្រោម ប្រើខេមសិច ផ្តល់លុយអោយច្រើន។
  - ក្រសួងធម្មការ និងសាសនាស្នើសុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ពិចារណាលើការគាំទ្រក្នុងការផ្សព្វផ្សាយមេរោគអេដស៍ និងជំងឺអេដស៍ តាមកម្មវិធីបុណ្យនានា។

**ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** បានធ្វើការបញ្ជាក់ថា តាមចំនួនប្រជាជន៨៣% នៃការឆ្លងមេរោគអេដស៍ថ្មី សរុបគឺស្ថិតក្នុងចំណោម ប្រជាជនគន្លឹះ បុរសរួមភេទជាមួយបុរស ស្ត្រីបំប្លែងភេទ អ្នកដែលប្រើប្រាស់និងចាក់ថ្នាំញៀន និងដៃគូផ្លូវភេទរបស់ពួកគេ។ សមិទ្ធិផលរបស់ប្រទេសកម្ពុជា ត្រូវបានចាត់ទុកជា ៤

គំរូក្នុងការសម្រេចបានខ្ពស់បំផុតនូវអត្រាទទួលសេវាព្យាបាល និងអត្រាកាត់បន្ថយមេរោគមកកម្រិតទាបបំផុតក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍។

នាឱកាសនោះ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការប្រធានអង្គប្រជុំបានបញ្ជាក់ថា នឹងទទួលយកសំណើនៅក្នុងកិច្ចប្រជុំដែលបានលើកឡើង និងលើកយកទៅចូលក្នុងកិច្ចប្រជុំពេញអង្គខាងមុខ ។ ឯកឧត្តមក៏បានបន្តថា ជាក់ស្តែងប្រទេសកម្ពុជាយើង នៅមានឧបសគ្គក្នុងការសម្រេចឱ្យបាននូវគោលដៅ៩៥ ទី១ ដែលនៅឆ្ងាយពីគោលដៅកំណត់ និងដែលទាមទារឱ្យយើងទាំងអស់គ្នាត្រូវបន្តរួមគ្នា រកវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពផ្សេងៗទៀត ដើម្បីសម្រេចគោលដៅនេះ។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ ប្រធានអង្គប្រជុំក៏បានបន្ថែមថា ការងារប្រយុទ្ធនឹងមេរោគអេដស៍ នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នា រវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងអ្នករងផលប៉ះពាល់។ ម្យ៉ាងទៀតត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិ ដែលរួមមានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យចំលើការងារជាអាទិភាព ពិសេសក្រុមប្រឈមមុខខ្ពស់ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ និងជាបណ្តើរៗជានាចីរភាព និងមានភាពធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងសូមជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយពីការបង្ការការចម្លងមេរោគអេដស៍ ដល់គ្រប់មជ្ឈដ្ឋាន ជាពិសេសក្រុមយុវវ័យ។

សម្រាប់កិច្ចប្រជុំបន្ទាប់នឹងកំណត់យក នៅថ្ងៃសុក្រ ៥កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅអាគារជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ(Zoom)៕

ថ្ងៃចន្ទ ១រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣

**បានពិនិត្យត្រឹមត្រូវ**

**ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

អ្នកធ្វើរបាយការណ៍

ប្រធានអង្គប្រជុំ

ហួន សៅវណ្ណ

**ស៊ុំ ផល្លា**

បណ្ឌិត **ឈឹម យិនដារ៉េត**